**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

## ឯកសារជំនួយស្មារតីគ្រូបណ្តុះបណ្តាល

# តួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ច

# ដល់ស្ត្រីក្នុងវិស័យកសិកម្ម

Gender Role and Women Economic Empowerment in Agriculture



**រៀបចំដោយៈ** កម្មវិធីផ្សព្វផ្សាយកសិកម្មថ្មីដែលធន់ទៅនឹង ការប្រែប្រួលអាកាសធាតុ (ASPIRE)

**ឧបត្ថម្ភដោយៈ** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

IFAD
Investing in rural people

**ភ្នំពេញ ខែ មីនា ឆ្នាំ ២០១៧**

# មាតិកា

ទំព័រ


សេចក្តីថ្លែងអំណរគុណ ........................................................................................4

ការណែនាំឲ្យស្គាល់គ្នាទៅវិញទៅមក ........................................................................5

សំណួរសាកល្បងមុនវគ្គបណ្តុះបណ្តាល......................................................................6

ការបង្ហាញពីគោលបំណង ការរំពឹងទុក និងរបៀបវារៈ ..................................................7

គោលការណ៍ក្រុម ឬ វគ្គ ........................................................................................9

គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្របញ្ជ្រាប យេនឌ័រក្នុងវិស័យកសិកម្ម និងតួនាទីភារកិច្ចអ្នកពាក់ព័ន្ធ ..........................................................................................................10

ការផ្តល់ ឬការបង្កើនសិទ្ធអំណាច ផ្នែកសេដ្ឋកិច្ចដល់ស្ត្រី .............................................14

លំហាត់ចាប់ផ្តើម ................................................................................................15

ផ្នត់គំនិតយេនឌ័រ ..............................................................................................17

ការវិភាគយេនឌ័រ................................................................................................21

ការរើសអើងទាក់ទងនឹងយេនឌ័រ ..........................................................................22

ការវិភាគ តួនាទីយេនឌ័រក្នុងរបរកសិកម្ម.................................................................22

យេនឌ័រ នឹងអំណាច.............................................................................................22

ការផ្តល់ភាពអង់អាចដល់ស្ត្រី ................................................................................26

សំណួរសាកល្បងក្រោយវគ្គបណ្តុះបណ្តាល..................................................................31

ការវាយតម្លៃដោយកសិករ .....................................................................................32

សំណួរសាកល្បង មុន និងក្រោយវគ្គបណ្តុះបណ្តាល ........................................................33

ទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល ប្រចាំថ្ងៃរបស់កសិករ....................................................................34
តារាងកំណត់ត្រាសង្ខេបលទ្ធផលនៃការពិភាក្សាតាមក្រុមសម្រាប់អ្នកសម្របសម្រួល ..........................35
វគ្គបណ្តុះបណ្តាល ស្តីពីតួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម ........................................................................................................................................38
ឯកសារយោង.........................................................................................................................43

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ មូលនិធិអន្តរជាតិអភិវឌ្ឍកសិកម្ម (IFAD) ដែលបានផ្តល់កម្ចីដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្ត កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) និងអង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (GCPSU-MAFF)ដែលបានចូលរួមពិនិត្យនិងផ្តល់ប្រឹក្សា។ ឯកសារណែនាំនេះគោលបំណង កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ របស់គ្រួសារ កសិករក្រីក្រ និងអ្នកងាយរងគ្រោះខ្នាតតូចនៅកម្ពុជា។ កម្មវិធីបានផ្តល់ថវិកា ដល់អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការអនុវត្ត សមាសភាពទី២ នៃកម្មវិធីគឺអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ក្រោមជាតិ និងមូលដ្ឋានតាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម និងគ្រប់គ្រងចំណេះដឹង និងពង្រឹងធនធានមនុស្សសម្រាប់ ផ្សព្វផ្សាយកសិកម្ម។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ មានគោលបំណងក្នុងការលើកកម្ពស់ឱកាសសេដ្ឋកិច្ចរបស់កសិករស្ត្រីក្រីក្រ ឲ្យកាន់តែមានភាពប្រសើរឡើង ដោយឆ្លងកាត់ការផ្តល់ឱកាសឲ្យស្ត្រីបញ្ចេញសម្លេង ធ្វើការសម្រេចចិត្តនៅក្នុងកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្ម។

យើងសង្ឃឹមថាឯកសារនេះ និងជួយដល់ មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយ ក្នុងការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្សផ្នែកយេនឌ័រ និងកសិកម្ម ក៏ដូចជាការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីជនបទ ។

ឯកសារណែនាំ "**តួនាទីយេនឌ័រនិងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម**" នេះជាសមិទ្ធិផលថ្មីមួយរបស់កម្មវិធី ASPIRE ភាពជោគជ័យក្នុងដំណើរ ការរៀបចំសៀវភៅនេះ គឺអាស្រ័យទាំងស្រុងលើកិច្ចសហប្រតិបត្តិការ និងការចូលរួមក្រុមការងារបច្ចេកទេស របស់កម្មវិធីនៃ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# ការណែនាំឲ្យស្គាល់គ្នាទៅវិញទៅមក

**គោលបំណង**: ដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមអាចៈ

- រៀបរាប់ឈ្មោះគ្នាទៅវិញទៅមក
- បង្កើតបរិយាកាសល្អ និងភាពស្និតស្នាលទៅវិញទៅមក

**វិធីសាស្រ្ត**:

- ចាប់ដៃគូ
- និយាយរឿងប្រាប់គ្នាទៅវិញទៅមក

**សម្ភារៈ**: ក្រដាសផ្ទាំងធំ ក្រដាសពណ៌កាត់ជារាងមូល ហ្វឺត ស្កុត

**រយៈពេល**: ១០ នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលសុំឲ្យអ្នកចូលរួមឈរជាពីរជួរ អ្នកដែលមានអាយុតិចជាងគេឈរមុខ ។ ចុងក្រោយសុំឲ្យអ្នកចូលរួមបែរមុខរកគ្នានឹងចាប់ដៃគូគ្នា

២. អ្នកសម្របសម្រួល ផ្តល់ជូននូវក្រដាសពណ៌ដែលកាត់ជារាងមូល និង ហ្វឺត ដើម្បីឲ្យគេសរសេរឈ្មោះ

៣. អ្នកសម្របសម្រួលសរសេរសំនួរដាក់លើក្រដាសផ្ទាំងធំ

- **តើអ្នកឈ្មោះអ្វី ?**
- **អ្នកណាជាអ្នកដាក់ឈ្មោះឲ្យអ្នក ?**

  បន្ទាប់មកឲ្យពួកគេសរសេរឈ្មោះឲ្យគ្នាទៅវិញទៅមកនៅលើក្រដាសរាងមូលដែលអ្នកសម្របសម្រួលចែកឲ្យ

៤. ពេលអស់ម៉ោង ស្នើឲ្យអ្នកចូលរួមឡើងមកបង្ហាញមួយគូរម្តងៗរហូតដល់អស់

- **តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះការចូលរួមធ្វើលំហាត់នេះ?**

៥. អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមពីគោលបំណងនៃលំហាត់នេះ គឺធ្វើឡើងដើម្បីបង្កើតឱកាសឲ្យអ្នកចូលរួមស្គាល់ឈ្មោះគ្នាទៅវិញទៅមក និងបង្កើនភាពស្និទ្ធស្នាលរវាងគ្នាផងដែរ។

# សំណួរសាកល្បងមុនវគ្គបណ្តុះបណ្តាល

**គោលបំណង**: ដើម្បីវាស់ស្ទង់ចំណេះដឹងរបស់កសិករមុនពេលទទួលវគ្គបណ្តុះបណ្តាល

**វិធីសាស្ត្រ**: អ្នកសម្របសម្រួលសួរសំណួរដែលបានសរសេររួចចំនួនបីសំណួរជារួម ដោយឲ្យសិក្ខាកាមលើកដៃឆ្លើយ និងសំណួរ និងកត់ចំនួនអ្នកឆ្លើយក្នុងក្រដាស

**សម្ភារះ**: ក្រដាសសំណួរសាកល្បង ប៊ិច ឬ ខ្មៅដៃ

**រយះពេល**: ១០នាទី

**ដំណើរការ**:

១.អ្នកសម្របសម្រួលប្រាប់សិស្សថា មុននិងចាប់ផ្តើមវគ្គ សូមអ្នកទាំងអស់គ្នាឆ្លើយដោយផ្ទាល់មាត់ ទៅនិងសំណួរដែលយើងទាក់ទងនិងមេរៀនដែលនិងបណ្តុះបណ្តាលក្នុងថ្ងៃនេះទាក់ទង និង ការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដើម្បីវាស់វែងចំណេះដឹងអ្នកទាំងអស់គ្នា

២.អ្នកសម្របសម្រួល កត់ត្រាចំនួនអ្នកឆ្លើយក្នុងក្រដាស

៣.អ្នកសម្របសម្រួលធ្វើការបូលសរុប និងដាក់ពិន្ទុត្រួសៗ ដើម្បីរៀបចំមេរៀនឲ្យឆ្លើយទៅនឹងចំណេះដឹងរបស់អ្នកចូលរួម

# ការបង្ហាញពីគោលបំណង ការរំពឹងទុក និងរបៀបវារៈ

**គោលបំណង**: ដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមអាចៈ

- កំណត់បាននូវគោលបំណងចម្បងរបស់វគ្គ និងប្រធានបទជាបន្តបន្ទាប់ដែល នឹងត្រូវលើកយកមកពិភាក្សា
- អ្នកចូលរួមនឹងអាចរៀបរាប់បាននូវអ្វីដែលគេគិតថាទទួលបានពីវគ្គបណ្តុះបណ្តាល

**វិធីសាស្ត្រ**:

- សំនួរបំផុសគំនិត ធ្វើបទបង្ហាញ និង
- អានឯកសារ

**សម្ភារៈ**: គោលបំណងនៃវគ្គសរសេរលើក្រដាសផ្ទាំងធំ ស្កុត

**រយៈពេល**: ១០នាទី

**ដំណើរការ**:

១.អ្នកសម្របសម្រួល ស្នើឲ្យអ្នកចូលរួមអង្គុយជាអក្សរ U ដើម្បីងាយស្រួលមើលគ្នាទៅវិញទៅមក

២.អ្នកសម្របសម្រួលនិយាយទៅកាន់អ្នកចូលរួមៈ

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) មានគោលបំណងក្នុងការលើកកម្ពស់ឱកាសសេដ្ឋកិច្ចរបស់ស្ត្រីកសិករក្រីក្រ ឲ្យកាន់តែមានភាពប្រសើរឡើង ដោយឆ្លងកាត់ការផ្តល់**ឱកាសឲ្យស្ត្រីបញ្ចេញសម្លេង និងធ្វើការសម្រេចចិត្ត**។

ដូច្នេះ គោលបំណងសំខាន់ក្នុងវគ្គនេះគឺៈ

- ធ្វើការឆ្លុះបញ្ចាំងអំពីការរស់នៅ ការប្រកបរបរចិញ្ចឹមជីវិត និងតួនាទីក្នុងសហគមន៍របស់ស្ត្រីក្រីក្រនៅតាមជនបទដែលបាត់បង់ឱកាស
- ស្វែងរក និងគៀងគរការចូលរួមគាំទ្រ ការលើកកម្ពស់ ការទទួលស្គាល់ និងឲ្យតម្លៃស្ត្រីក្នុងសកម្មភាពចូលរួមរកប្រាក់ ចំណូល និងសកម្មភាពដឹកនាំក្រុម ឬសហគមន៍ ពីសំណាក់ដៃគូរបុរស សហគមន៍ មន្ទីរវិស័យ និងអាជ្ញាធមូលដ្ឋាន

៣. អ្នកសម្របសម្រួល បង្ហាញដោយសង្ខេប ពីគោលបំណងនៃវគ្គបណ្តុះបណ្តាលដូចក្នុងក្រដាសផ្ទាំងធំ ។ សុំឲ្យសិស្សដែលស្ម័គ្រចិត្ត ២ ទៅ ៣នាក់ អាននូវចំណុចទាំងនោះ

៤. បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញនូវរបៀបវារៈក្នុងវគ្គ

៥. អ្នកសម្របសម្រួលប្រាប់អ្នកចូលរួម អំពីអ្វីដែលគេនឹងទទួលបាន ពីវគ្គបណ្តុះបណ្តាលនេះដូចជា ចំណេះដឹងការចែករំលែកបទពិសោធន៍ ពីគ្នាទៅវិញទៅមក សម្ភារៈមេរៀន អាហារសម្រន់ជាដើម។

# គោលការណ៍ក្រុម ឬ វគ្គ

**គោលបំណង**: ដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមអាចៈ

- មានការឯកភាពគ្នាលើគោលការណ៍សម្រាប់វគ្គដើម្បីឲ្យមានការចូលរួម និងសហការគ្នា

**វិធីសាស្ត្រ**:

- សំនួរបំផុសគំនិត
- សរសេរលើក្រដាសផ្ទាំងធំ
- ក្រដាសរូបអាក្បកិរិយា ដែលអ្នកចូលរួមមិនគួរធ្វើ

**សម្ភារៈ**: ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត

**រយៈពេល**: ៥ នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលបំផុសគំនិតទៅអ្នកចូលរួម ដើម្បីឲ្យវគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅបានល្អ តើយើងត្រូវកំណត់នូវគោលការណ៍ ឬ វិន័យក្រុមយ៉ាងដូចម្តេច ?

២. អ្នកសម្របសម្រួលទុកពេលសម្រាប់អ្នកចូលរួមពិភាក្សា និងផ្តល់យោបល់

៣. អ្នកសម្របសម្រួលបង្ហាញអ្នកចូលរួមថា គោលការណ៍ទាំងនេះគឺយើងជាអ្នកកំណត់ទាំងអស់គ្នា ដូច្នេះត្រូវគោរពទាំងអស់គ្នារហូតដល់ពេលចប់វគ្គ

៤. អ្នកសម្របសម្រួលបង្ហាញអ្នកចូលរួមអំពីរូបភាពមួយចំនួនដែលអ្នកចូលរួមមិនគួរធ្វើកំឡុងពេលចូលរួមវគ្គបណ្តុះបណ្តាល



**មិននិយាយតែឯង**



**មិនយកចិត្តទុកដាក់**



**មិននិយាយគ្នាពេលរៀន**



**មិននិយាយទូរស័ព្ទ**

# គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្របញ្ជ្រាប យេនឌ័រក្នុងវិស័យកសិកម្ម និងតួនាទីភារកិច្ចអ្នកពាក់ព័ន្ធ

**គោលបំណង:**

- រៀបរាប់បាននូវគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម
- បង្កើនការយល់ដឹងសម្រាប់អនុវត្តន៍ជាក់ស្តែងក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងយុទ្ធសាស្ត្រនានារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កំណត់តួនាទី និងភារកិច្ចនានារបស់អ្នកពាក់ព័ន្ធថ្នាក់ក្រោមជាតិ ក្នុងវិស័យកសិកម្មក្នុងការអនុវត្ត គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យ កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**រយៈពេល**: ២ម៉ោង ៣០នាទី

**សម្ភារៈ**: ក្រដាសផ្ទាំងធំ ហ្វឺត បង់ស្អិត ក្រដាសពណ៌

**វិធីសាស្ត្រ**: ធ្វើបទបង្ហាញ ពន្យល់ បំផុសគំនិត និងក្រុមពិភាក្សា

**ដំណើរការ/សកម្មភាព**:

**សកម្មភាពទី១**: គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម (រយៈពេល ១ ម៉ោង)

I. អ្នកសម្របសម្រួលធ្វើបទបង្ហាញសង្ខេបពី ខ្លឹមសារនៃគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម

II. នៅក្នុងបទបង្ហាញអ្នកសម្របសម្រួលបានលើកឡើងនូវចំណុចគន្លឹះនៃគោលនយោបាយ និងក្របខ័ណ្ឌដូចខាងក្រោម៖

**ទស្សនៈវិស័យ**: គាំទ្រការលើកកម្ពស់សមភាពយេនឌ័រ និងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី កម្ពុជា តាមរយៈការចូលរួមយ៉ាងសកម្ម និងភាពជាតំណាងរបស់ស្ត្រី និងបុរសសម្រាប់ឱកាសរួមចំណែក និងទទួល បានផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចកសិកម្ម ផ្អែកលើអភិក្រមប្រកបដោយ ប្រសិទ្ធភាពលើផលិតកម្ម ពិពិធកម្ម ខ្សែសង្វាក់តម្លៃ ពាណិជ្ជូបណីយកម្ម និងការអភិរក្សនិង គ្រប់គ្រង ធនធានធម្មជាតិប្រកបដោយ និរន្តភាព។

**បេសកកម្ម**: ពង្រឹងឥទ្ធពលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើសមភាពយេនឌ័រនៅក្នុងគ្រប់ វិស័យការងារ ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង ផលិតកម្មកសិកម្ម ការផ្លាស់ប្តូរចំណេះដឹង ការ

ស្រាវជ្រាវ និងគុណភាពសេវាផ្សព្វផ្សាយ និងការបន្ថែមតម្លៃលើការឆ្លើយតបយេនឌ័រ ដែលជាមូលដ្ឋានដ៏ មាន ប្រសិទ្ធិភាព និងសមធ៌មលើវិស័យកសិកម្ម។

**គោលដៅ**: ធានានូវការបញ្ជ្រាបទស្សនៈ ការវិភាគ ក្បួនខ្នាត បទដ្ឋាន និងអភិក្រមយេនឌ័រនៅក្នុងការងាររបស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅគ្រប់កម្រិត។

**គោលបំណង**:

១. លើកកម្ពស់សិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតាមរយៈលទ្ធភាពស្ត្រី ក្នុងការទទួលបានធនធាន និងសេវាកម្មសម្រាប់ការអភិវឌ្ឍកសិកម្ម និងទីផ្សារកសិកម្ម

២. ពង្រឹងសមត្ថភាព ធនធាន និងការប្តេជ្ញារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធានានូវប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យកសិកម្ម

៣. បង្កើនភាពជាតំណាងនិងការចូលរួមដោយស្មើភាពគ្នាទាំងបុរស និងស្ត្រីក្នុងវិស័យកសិកម្ម។

III. ក្រោយបញ្ចប់ការធ្វើបទបង្ហាញ អ្នកសម្របសម្រួលបានសួរទៅសិក្ខាកាម តើមានអ្នកណាម្នាក់មានសំណួរ ឬត្រូវការឲ្យមានការបកស្រាយបន្ថែមដែរឬទេ?

IV. អ្នកសម្របសម្រួលធ្វើការបញ្ជាក់បន្ថែមដល់អ្នកចូលរួមថា៖ ចំណុចនិងទស្សនៈសំខាន់ៗដែលបានគ្រប់ដណ្តប់ក្នុងវគ្គបណ្តុះបណ្តាលនេះបានឆ្លុះបញ្ចាំងអំពីគោលបំណងនានានៃគោលនយោបាយដែលពាក់ព័ន្ធ។

**សកម្មភាពទី ២**: តួនាទីភារកិច្ចអ្នកពាក់ព័ន្ធ (រយៈពេល ១ ម៉ោង ៣០ នាទី)

សកម្មភាពនេះ អាចនឹងជួយដល់អ្នកពាក់ព័ន្ធនានាក្នុងវិស័យកសិកម្ម ដើម្បីបង្កើនការ យល់ដឹងថាពួកគេអាចនឹងចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម យ៉ាងដូចម្តេច?

១. អ្នកសម្របសម្រួលសង្ខេបពីខ្លឹមសារនៃគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ ឡើងវិញ និងគូសជាដ្យាក្រាមបង្ហាញពីទំនាក់ទំនងរបស់អ្នកពាក់ព័ន្ធ និងតួនាទីរបស់ពួកគេ។

## គោលនយោបាយយេនឌ័រ

- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រុមការងារយេនឌ័រ និងកុមារ

តួនាទី៖ បង្កើតគោលនយោបាយ និងផែនការសកម្មភាព




## កម្មវិធី

- អង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារ
- អង្គភាពក្រោមឱវាទក្រសួង ៖អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ, រដ្ឋបាលព្រៃឈើ, រដ្ឋបាលជលផល ,អគ្គនាយកដ្ឋានកសិកម្ម, អគ្គនាយកដ្ឋានកៅស៊ូ...

**តួនាទី៖**

- ផ្សព្វផ្សាយគោលនយោបាយ
- រៀបចំសម្របសម្រួកការអនុវត្តគម្រោង
- រៀបចំគម្រោងថវិកា
- កៀរគរធនធាន
- ត្រួតពិនិត្យ និងវាយតម្លៃ

## ការអនុវត្ត

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២៥ ខេត្ត-ក្រុង
- ការិយាល័យកសិកម្មស្រុក
- ភ្នាក់ងារផ្សព្វផ្សាយឃុំ /ភូមិ
- ជនបង្គោលយេនឌ័រនិងកុមារថ្នាក់ខេត្ត
- ខណ្ឌរដ្ឋបាលជលផល ពេទ្យសត្វភូមិ សហគមន៍
- គ.ក.ន.ក និងគកសក

**តួនាទី៖**

- ផ្សព្វផ្សាយគោលនយោបាយ
- រៀបចំនិងអនុវត្តផែនការសកម្មភាព
- កៀរគរធនធាន
- ត្រួតពិនិត្យនិងវាយតម្លៃ
- របាយការណ៍

២. បន្ទាប់មកអ្នកសម្របសម្រួលបញ្ជាក់បន្ថែមពីតួនាទីភារកិច្ចរបស់អ្នកពាក់ព័ន្ធនីមួយៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយនឹងការចោទសួរសំណួរបំផុសគំនិត និងចំលើយពី សិក្ខាកាម។

៣. ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀតអ្នកសម្របសម្រួល បែងចែកសិក្ខាកាមជាបីក្រុម ដើម្បីធ្វើការពិភាក្សាលើប្រធានបទចំនួនបីដូចខាងក្រោម៖

- តើត្រូវធ្វើដូចម្តេច ដើម្បីអោយវគ្គផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បានផ្តល់ផលប្រយោជន៍ពិតប្រាកដដល់ស្ត្រី
- តើត្រូវធ្វើដូចម្តេច ដើម្បីអោយការងារកសិកម្ម ផ្តល់ផលប្រយោជន៍បានច្រើនបំផុតដល់កុមារ
- តើគួររៀបចំយ៉ាងដូចម្តេច ដើម្បីឱ្យសមាគមន៍កសិកម្ម ផ្តល់ផលប្រយោជន៍ពិតប្រាកដដល់ស្ត្រីជាសមាជិក

៤. អ្នកសម្របសម្រួលពន្យល់ពីរបៀបអនុវត្តលើការងារដែលត្រូវធ្វើ និងសំណួរ

៥. ទុកពេលវេលា អោយអ្នកចូលរួមពិភាក្សាក្រុមរយះពេល ១៥ នាទី

៦. ក្រុមពិភាក្សានីមួយៗធ្វើបទបង្ហាញលទ្ធផលក្រុមពិភាក្សា រយះពេល ១០នាទី

៧. អ្នកសម្របសម្រួលធ្វើការបូកសរុប។

# ការផ្តល់ ឬការបង្កើនសិទ្ធអំណាច ផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

## គោលបំណងៈ

- យល់ដឹងពីតួនាទីនិងការចូលរួមអនុវត្តសកម្មភាពការងារកសិកម្ម របស់បុរសនិងស្ត្រី
- ដើម្បីលើកកម្ពស់ការយល់ដឹងតួនាទីយេនឌ័រ និងការខុសគ្នារបស់បុរស និងស្ត្រីពីចូលរួមសកម្មភាពនានា
- ធ្វើការឆ្លុះបញ្ចាំងអំពីការរស់នៅ ការប្រកបរបរចិញ្ចឹមជីវិត ការផលិតដំណាំកសិកម្ម និងតួនាទីក្នុងសហគមន៍របស់ស្ត្រីក្រីក្រ ដែលផលិតដំណាំកសិកម្មខ្នាតតូច
- ស្វែងរក និងគៀងគរការចូលរួមគាំទ្រ ការលើកកម្ពស់ ការទទួលស្គាល់ និងឲ្យតម្លៃស្ត្រីក្នុងសកម្មភាពចូលរួមរកប្រាក់ ចំណូល និងសកម្មភាពដឹកនាំក្រុម ឬសហគមន៍ ពីសំណាក់ដៃគូរបុរស សហគមន៍ មន្ទីរវិស័យ និងអាជ្ញាធរមូលដ្ឋាន។

# លំហាត់ចាប់ផ្តើម

**គោលបំណង**: បង្ហាញពីមូលហេតុនៃការយកចិត្តទុកដាក់លើស្ត្រី

**វិធីសាស្ត្រ**:

- ពិភាក្សាក្រុម
- សរសេរលើក្រដាសផ្ទាំងធំ
- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់

**សម្ភារៈ**: ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត

**រយៈពេល**: ៣០ នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលបង្ហាញពីចំណងជើង និងគោលបំណងមេរៀន

**២. ហេតុអ្វីផ្តោតសំខាន់លើស្ត្រី (៣០នាទី)**

- អ្នកសម្របសម្រួលចែកអ្នកចូលរួមជា២ក្រុម (ក្រុមប្រុស និងក្រុមស្រី) ដើម្បីធ្វើការពិភាក្សា

**ក្រុមទី១ ធ្វើលំហាត់ទី១**: នៅក្នុងសហគមន៍របស់លោកអ្នក តើបុរសភាគច្រើនធ្វើកិច្ចការអ្វី?

**ក្រុមទី២ ធ្វើលំហាត់ទី២**: នៅក្នុងសហគមន៍របស់លោកអ្នក តើស្ត្រីភាគច្រើនធ្វើកិច្ចការអ្វី?

- ទុកពេល២០នាទីសម្រាប់ការពិភាក្សា។ អស់ម៉ោង ស្នើឲ្យក្រុមទាំង២ឡើងបង្ហាញ។ ទុកពេល១០នាទីសម្រាប់ការបំពេញបន្ថែម
- ថ្លែងអំណរគុណចំពោះការចូលរួមធ្វើលំហាត់របស់ក្រុមទាំង២ អ្នកសម្របសម្រួលធ្វើការសំយោគតាមលទ្ធផលជាក់ស្តែងដែលបានមកពីការពិភាក្សា
- អ្នកសម្របសម្រួលបង្ហាញ៖

នៅតាមសហគមន៍នានា ស្ត្រី និងកុមារីគឺជាអ្នកងាយរងគ្រោះជាងគេ។ ប្រសិនបើគ្រួសារក្រី ក្រមិនអាច ឲ្យកូនៗទៅរៀនបាន អ្នកដែលត្រូវឈប់មុនគេគឺជាក្មេងស្រី។ ប្រសិនបើនិយាយអំពី អំពើហឹង្សានោះស្ត្រីភាគច្រើនគឺជាជនរងគ្រោះ។ ប្រសិនបើសំដៅលើតួនាទីជាអ្នកដឹកនាំ តាមសហគមន៍ភាគច្រើនគឺជាបុរស។ រហូតមកដល់បច្ចុប្បន្ននេះបញ្ហាប្រឈម ឬកង្វល់នានារបស់ ស្ត្រីនៅមិនទាន់បានដោះស្រាយអស់នៅឡើយទេ។ អ្វីដែលសំខាន់គឺ ប្រសិនបើស្ត្រីទន់ខ្សោយ នោះបន្ទុកជាច្រើននឹងធ្លាក់ទៅលើបុរសជាអ្នកទទួលខុសត្រូវ។

- អ្នកសម្របសម្រួលទាញភ្ជាប់ទៅមេរៀនខាងក្រោយថា យើងនឹងធ្វើការពិភាក្សា និងឆ្លុះបញ្ចាំងទាំងអស់គ្នា ថាតើហេតុអ្វីបានជាស្ថានភាពផ្សេងៗរបស់ស្ត្រីមិនទាន់បានល្អប្រសើរដូចបុរស? តើយើងអាចជួយស្ត្រីតាមវិធីណា?

# ផ្ទត់គំនិតយេនឌ័រ

**គោលបំណង**:

- សិក្សាពីនិយមន័យនៃយេនឌ័រ ភេទ សមធ៌មយេនឌ័រ និង សមភាពយេនឌ័រ ដោយឆ្លុះបញ្ចាំងពីស្ថានភាពពិតក្នុងសហគមន៍
- សិក្សាពីទំហំនៃការទទួលខុសត្រូវប្រចាំថ្ងៃរបស់ស្ត្រី

**វិធីសាស្ត្រ**:

- សំនួរបំផុសគំនិត   លំហាត់ក្រុម
- ពិភាក្សាដោយប្រើរូប សរសេរលើក្រដាសផ្ទាំងធំ
- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់

**សម្ភារៈ**:   ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត ផ្ទាំងរូប

**រយៈពេល**:   ៧០នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលបង្ហាញពីចំណងជើង និងគោលបំណងមេរៀន

**២. លំហាត់ពីភេទ យេនឌ័រ សមភាពយេនឌ័រ និងសមធ៌មយេនឌ័រ (៣៥នាទី)**

- អ្នកសម្របសម្រួលបិទក្រដាសផ្ទាំងធំ ដែលមានគូសតារាង២ និងបិទរូប ស្ត្រី និងបុរស

|  |  |
|---|---|
| | |

- បង្ហាញផ្ទាំងរូបភាពមួយចំនួនដល់អ្នកចូលរួម



- ឲ្យអ្នកចូលរួមជ្រើសរើសបិតរូបទាំងនោះក្នុងកូឡោនស្ត្រី ឬកូឡោនបុរស

- អ្នកសម្របសម្រួលសួរអ្នកចូលរួមថា
  - តើសកម្មភាពណាមួយដែលស្ត្រីធ្វើបាន តែបុរសមិនអាចធ្វើបាន?
  - តើសកម្មភាពណាមួយដែលស្ត្រីមិនអាចធ្វើបាន តែបុរសធ្វើបាន?
  - តើសកម្មភាពសកម្មភាពណាមួយដែលទាំងស្ត្រី ទាំងបុរសអាចធ្វើបានដូចគ្នា?
- អ្នកសម្របសម្រួលធ្វើការសំយោគលទ្ធផលៈ

ឆ្លងតាមលំហាត់ខាងលើ យើងឃើញថា ស្ត្រី និងបុរស ខុសគ្នាតែភេទតែប៉ុណ្ណោះ ព្រោះវាជាកត្តាជីវសាស្ត្រ ដែលមានតាំងពីកំណើត ហើយមិនអាចផ្លាស់ប្តូរបាននោះទេ។

(លើករូបនេះបង្ហាញ)




ក្រៅពីកត្តាភេទនេះ ទាំងស្ត្រី ទាំងប្រុស មានសិទ្ធិស្មើគ្នាតាំងពីកំណើត រស់នៅស្មើភាពគ្នា និងមានសមត្ថភាពដូចគ្នាក្នុងការធ្វើកិច្ចការនានា និងទទួលផលស្មើគ្នាចំពោះការងារដូចគ្នា ។

(លើករូបនេះបង្ហាញ)



ប៉ុន្តែស្ត្រីមួយចំនួននៅតែមិនបានទទួលការឲ្យតម្លៃពីគ្រួសារ និងសហគមន៍ ព្រោះគេគិតថាស្ត្រីមិនអាចធ្វើ កិច្ចការធំដំដូចបុរស ដោយសារតែស្ត្រីមិនមានសមត្ថភាព ឬស្ត្រីវិលចង្ក្រានមិនជុំ។

(លើករូបនេះបង្ហាញ)




- អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមថា យើងនាំគ្នាគិតទាំងអស់គ្នា ថាហេតុអ្វីបានជាស្ត្រីនៅតែមិនអាចធ្វើកិច្ចការផ្សេៗ ឬមិនអាចកាន់តួនាទីធំដូចជាបុរស?

**៣. លំហាត់ពីការងារ ២៤ម៉ោង របស់ស្ត្រី (៣៥នាទី)**

- អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមថា យើងចាប់ផ្តើមគិតការងារទទួលខុសត្រូវប្រចាំថ្ងៃរបស់ស្ត្រី
- អ្នកសម្របសម្រួលសួរសំនួរ តើក្នុង១ថ្ងៃ ស្ត្រីត្រូវធ្វើកិច្ចការអ្វីខ្លះ?
- អ្នកសម្របសម្រួលបិតក្រដាសផ្ទាំងធំដែលមានរូបស្ត្រីនៅកណ្តាល រួចកត់ត្រាចម្លើយរបស់អ្នកចូលរួមទាំងអស់ជុំវិញរូបនោះ

**ឧទាហរណ៍៖**



- អស់ម៉ោង
- សុំឲ្យអ្នកចូលរួមបង្ហាញពីចំណាប់អារម្មណ៍របស់គេចំពោះលទ្ធផលដែលបានបង្ហាញលើក្រដាស
- នៅចុងបញ្ចប់ការឆ្លើយ អ្នកសម្របសម្រួលសំយោគលទ្ធផលដូចខាងក្រោមៈ

| |
|---|
| តាមរយៈលំហាត់យើងដឹងហើយថា ក្នុង១ថ្ងៃស្ត្រីត្រូវទទួលខុសត្រូវលើកិច្ចការជាច្រើនមុខ។ មានអ្នកខ្លះ បានហៅស្ត្រីថាមានដៃ១០០ ព្រោះតែស្ត្រីមានការងារច្រើនដែលត្រូវធ្វើ។ ចំណុចនេះ គឺជាហេតុផលមួយដែលធ្វើឲ្យស្ត្រីមិនមានឱកាសគ្រប់គ្រាន់ដើម្បីចូលរួមក្នុងកិច្ចការផ្សេងៗនៅក្នុងសហគមន៍ និងបាត់បង់ឱកាសទទួលបានព័ត៌មាន ចំណេះដឹង ទំនាក់ទំនងពង្រីក ការងារអាជីវកម្ម មុខរបរចិញ្ចឹមជីវិត និងឋានៈតួនាទីនៅក្នុងសហគមន៍។ |

(លើករូបនេះបង្ហាញ)




- អ្នកសម្របសម្រួលបន្តសំណួរ ក្រៅពីការងារផ្ទះសម្បែងដ៏មមាញឹក តើនៅមានបញ្ហាអ្វីខ្លះទៀតដែលរាំងស្ទះស្ត្រី?

# ការវិភាគយេនឌ័រ

**គោលបំណង**:

- ពិភាក្សាពីចំណេះដឹងស្តីពី សារៈប្រយោជន៍នៃការវិភាគយេនឌ័រ
- ឆ្លុះបញ្ចាំងពីគុណតម្លៃផ្សេងៗដែលកើតមានក្នុងសង្គមចំពោះបុរស ឬស្ត្រី ដែលបណ្តាលមក ពីការគិតរបស់មនុស្ស

**វិធីសាស្ត្រ**:

- លំហាត់សន្ទនាស្វែងយល់ពីផ្នត់គំនិតរបស់អ្នកចូលរួម
- សំនួរបំផុសគំនិត   សរសេរលើក្រដាសផ្ទាំងធំ
- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់

**សម្ភារៈ**:     ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត ផ្ទាំងរូប

**រយៈពេល**:  ៦០នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលបង្ហាញពីចំណងជើង និងគោលបំណងមេរៀន

**២. លំហាត់ស្វែងយល់ពីផ្នត់គំនិតរបស់អ្នកចូលរួមចំពោះតួនាទីយេនឌ័រ (៣០នាទី)**

- អ្នកសម្របសម្រួលបែងចែកបន្ទប់រៀនជាពីរផ្នែក ដោយម្ខាង"**យល់ស្រប**" និងម្ខាងទៀត "**មិនយល់ស្រប**"
- ឱ្យអ្នកចូលរួមទាំងអស់ក្រោកឈរឡើង ហើយពន្យល់ថាលំហាត់នេះ នឹងឱ្យពួកគេគិត ហើយសម្រេចចិត្តដោយផ្អែកលើការយល់ឃើញផ្ទាល់ខ្លួន។ ពួកគេគួរសម្រេចចិត្តឈរនៅកន្លែងណាដែលពួកគេយល់ឃើញ

**ប្រយោគទី ១៖** "វាជារឿងធម្មតា ប្រសិនបើស្ត្រីមិនជួយរកប្រាក់ចំណូល និងរស់នៅពឹងលើប្តី"
**ប្រយោគទី ២៖** "បុរសអាចទៅរកស៊ីនៅឆ្ងាយបាន ឯស្ត្រីវិញមិនអាចទៅបានទេ"
**ប្រយោគទី ៣៖** "ស្ត្រីមិនអាចចាត់ចែងការងារបានល្អដូចបុរសទេ"
**ប្រយោគទី ៤៖** "បុរសស័ក្កសមកាន់តួនាទីធំៗក្នុងសហគមន៍ ដូចជាមេឃុំ ឬមេភូមិជាដើមព្រោះបុរស មានសមត្ថភាព និងមានពេលវេលាគ្រប់គ្រាន់"
**ប្រយោគទី ៥៖** "ទោះស្ត្រីធ្វើជាមេភូមិ មេឃុំ ឬអ្នកដឹកនាំសហគមន៍ ក៏មិនអាចធ្វើការបានល្អដូចបុរសដែរ"

- អ្នកសម្របសម្រួលចាប់ផ្តើមអានប្រយោគទី១ ។ ក្រោយពីអ្នកចូលរួមទាំងអស់ឈរនៅទីតាំងរបស់ខ្លួនហើយ អ្នកសម្របសម្រួលនាំពួកគេពិភាក្សា រកហេតុផលនៃទីតាំងដែលពួកគេឈរ ហើយធ្វើការបកស្រាយ
- ក្រោយពីការពិភាក្សា អ្នកសម្របសម្រួលប្រាប់ទៅអ្នកចូលរួមថា ប្រសិនបើពួកគេចង់ប្តូរទីតាំងឈរ គឺគេអាចប្តូរបាន

❖ នេះជាការសន្ទនាមួយ ដោយអ្នកសម្របសម្រួលឱ្យអ្នកចូលរួមស្វែងរកនូវចំណេះដឹងទាក់ទងនឹងតួនាទីយេនឌ័រក្នុងសង្គម ។ការបញ្ចេញមតិយោបល់អាចមានភាពតានតឹងខ្លះព្រោះបុគ្គលម្នាក់ៗចង់ការពារអ្វីដែលខ្លួននិយាយ ដូច្នេះអ្នកសម្របសម្រួលត្រូវធ្វើយ៉ាង ណាកុំឲ្យអ្នកចូលរួមជជែកយកឈ្នះរៀងៗខ្លួន ត្រូវឲ្យពួកគាត់គិតថានេះជាការចែករំលែក ព័ត៌មាន និងការយល់ឃើញទៅវិញទៅមក។

- អ្នកសម្របសម្រួលពន្យល់ថា៖

លំហាត់នេះ គឺចង់ស្វែងយល់អំពីផ្នត់គំនិតរបស់យើងម្នាក់ៗចំពោះតួនាទីរបស់បុរសនិងស្ត្រី នៅក្នុងសង្គម ដែលផ្នត់គំនិតទាំងនេះពិតជាមានឥទ្ធិពលលើស្ត្រី និងបុរសដែលរស់នៅក្នុងសង្គម។ ផ្នត់គំនិតខ្លះត្រឹមត្រូវ តែផ្នត់គំនិតខ្លះមិនត្រឹមត្រូវទេ ហើយថែមទាំងបានធ្វើឲ្យស្ត្រីក្លាយជាជនរងគ្រោះនៃអំពើហឹង្សា ធ្វើឲ្យក្មេងស្រីមិនបានទទួលនូវការអប់រំពេញលេញ មិនអាចទទួលបាននូវសេវាថែទាំសុខភាពត្រឹមត្រូវ និងបាត់បង់ឱកាសក្នុងការចូលរួមរកប្រាក់ចំណូល និងបាត់បង់ឱកាសកាន់តួនាទីជាអ្នកដឹកនាំក្នុង សហគមន៍ជាដើម។

## ៣. ការពិភាក្សាស្វែងរកផ្នត់គំនិតរបស់អ្នកចូលរួម និងសហគមន៍ចំពោះតួនាទីយេនឌ័រ (៣០នាទី)

- អ្នកសម្របសម្រួលសួរអ្នកចូលរួមថា
- តើពូ មីង គិតយ៉ាងម៉េច ប្រសិនបើមនុស្សស្រីធ្វើកិច្ចការខុសពីការងារដែលស្ត្រីធ្វើប្រចាំថ្ងៃ ដូចជាធ្វើជាជាងជួលជុលទូរសព្ទ័ ជាងជួសជុលវិទ្យុ ទូរទស្សន៍ ម្ចាស់កសិដ្ឋាន ជាដើម?
- អ្នកសម្របសម្រួលទុកពេល២០នាទីសម្រាប់ការឆ្លើយ។ កត់ត្រាចម្លើយអ្នកចូលរួមដាក់លើក្រដាសផ្ទាំងធំ

អ្នកសម្របសម្រួលសួរដេញបន្ត៖

– ប្រសិនបើក្រឡេកមើលស្ថានភាពជាក់ស្តែង ហេតុអ្វីបានជាភាគច្រើនជាងជួលជុលទូរសព្ទ័ ជាងជួសជុលវិទ្យុ ទូរទស្សន៍ មេឃុំ ឬមេភូមិគឺជាបុរស?

អ្នកសម្របសម្រួលត្រូវកត់ចម្លើយទាំងនោះទុក ព្រោះវាបង្ហាញពីការឲ្យតម្លៃរបស់អ្នកចូលរួម ឬសហគមន៍នោះចំពោះការងាររបស់ស្ត្រី។

- អ្នកសម្របសម្រួលពន្យល់ថា:

ទង្វើរបស់មនុស្សគឺធ្វើតាមអ្វីដែលខ្លួនគិត ឬធ្វើតាមទម្លាប់។ គំនិតខ្លះថាស្ត្រីអាចធ្វើការទាំងនោះបាន គំនិតខ្លះថាស្ត្រីមិនសមធ្វើកិច្ចការទាំងនោះទេព្រោះស្ត្រីគ្មានសមត្ថភាព ទោះស្ត្រីកំពុងកាន់តួនាទីដូចបុរសក៏ដោយ។ ហើយពេលខ្លះស្ត្រីខ្លួនឯងក៏មិនបានគិតវែង ឆ្ងាយ ធ្វើតាមតែអ្វីដែលជាទម្លាប់ មិនហ៊ានធ្វើការតវ៉ា ឬមិនហ៊ានលើកទឹកចិត្តស្ត្រីគ្នាឯងក៏មាន។ ដូច្នេះហើយបានជាស្ត្រីមួយចំនួននៅតែមិនអាចធ្វើកិច្ចការផ្សេងៗបានពេញលេញដោយ សារតែផ្នត់គំនិតរាំងស្ទះមួយចំនួន។

# ការរើសអើងទាក់ទងនឹងយេនឌ័រ

**គោលបំណង**:

- បណ្ដុះគំនិតមិនរើសអើង និងមិនគៀបសង្កត់ស្ដ្រី ពីសំណាក់ប្ដី ក្រុមគ្រួសារ និងសហគមន៍ ដែលសកម្មភាពនៃការរើសអើង និងគៀបសង្កត់ផ្សេងៗត្រូវបានចាត់ទុកជាអំពើហឹង្សាមកលើស្ដ្រី

**វិធីសាស្ដ្រ**:

- សំនួរបំផុសគំនិត ពិភាក្សាក្រុម បង្ហាញរូប
- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់

**សម្ភារៈ**: ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត រូប

**រយៈពេល**: ៦០នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលបង្ហាញពីចំណងជើង និងគោលបំណងមេរៀន

**២. លំហាត់ស្វែងយល់ពីផលវិបាកផ្សេងៗរបស់ស្ដ្រីដែលកើតពីការគៀបសង្កត់ និងរើសអើងពីសំណាក់ប្ដី ក្រុមគ្រួសារ និងសហគមន៍ (៤០នាទី)**

- អ្នកសម្របសម្រួលសួរអ្នកចូលរួម៖

> តើក្រៅពីការងារផ្ទះសម្បែង និងផ្ដត់គំនិតមួយចំនួនដែលរាំងស្ទះស្ដ្រី តើស្ដ្រីទទួលរងនូវការគៀបសង្កត់ ឬការរើសអើងអ្វីខ្លះទៀត?

- អ្នកសម្របសម្រួលទុកពេល៣០នាទីសម្រាប់ការឆ្លើយ។ កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។
- អ្នកសម្របសម្រួលធ្វើការសំយោគ៖

> មានក្រុមគ្រួសារ និងសហគមន៍ខ្លះមិនបានផ្ដល់ឱកាសឲ្យស្ដ្រីចូលរួមវគ្គបណ្ដុះបណ្ដាល ឬចូលរួមសកម្មភាពផ្សេងៗទៀតតាមសហគមន៍នោះទេដោយសារពួកគេគិតថាមិនចាំបាច់ឬមិនមានប្រយោជន៍។ មានពេលខ្លះពួកគេស្ដីបន្ទោស ឬប្រើពាក្យមិនសមរម្យ ឬឈានទៅរកការវាយដំស្ដ្រីប្រសិនបើស្ដ្រីនៅតែចចេសមិនធ្វើតាម។

**៣. ពន្យល់អំពីការ មិនរើសអើង និងមិនគៀបសង្កត់ស្ដ្រី (២០នាទី)**

ជាការពិត ស្ដ្រីអាចធ្វើការងារជាច្រើន ក្រៅពីការងារផ្ទះសម្បែង ដូចជាធ្វើអ្នកដឹកនាំកសិដ្ឋាន ឈ្មួញលក់ដូរ ម្ចាស់អាហារដ្ឋាន ឈ្មួញកណ្ដាល ជាងជួសជុលទូរសព្ទ ជាងជួសជុលទូរទស្សន៍ ឬវិទ្យុជាដើម ប្រសិនបើស្ដ្រីមានសមត្ថភាព និងមានពេលវេលាគ្រប់គ្រាន់...ដូច្នេះ គេមិនត្រូវរើសអើង មិនត្រូវគៀបសង្កត់ ឬមិនផ្ដល់ឱកាស មិនផ្ដល់តម្លៃដល់ស្ដ្រីនោះទេ ព្រោះសកម្មភាពទាំងនោះគឺជាអំពើហឹង្សាលើស្ដ្រី។

(លើករូបនេះបង្ហាញ)


ស្ត្រីអាចធ្វើកិច្ចការជាច្រើនក្រៅពីការងារផ្ទះសម្បែង ដូចជាអ្នកដឹកនាំ
កសិដ្ឋាន ឈ្មួញលក់ដូរ ម្ចាស់អាហារដ្ឋាន ឈ្មួញកណ្តាល ជាងជួស
ជុលទូរសព្ទ័ ទូរទស្សន៍ ឬវិទ្យុជាដើមឌ គេមិនត្រូវរើសអើង
គៀបសង្កត់ស្ត្រីមិនឱ្យបំពេញការងារទាំងនោះទេ
ព្រោះសកម្មភាពទាំងនោះគឺជាអំពើហិង្សា
ទៅលើស្ត្រី

# ការវិភាគ តួនាទីយេនឌ័រក្នុងរបរកសិកម្ម

**គោលបំណង**

- ការវិភាគតួនាទីយេនឌ័រគឺ វាយតម្លៃ ពីតួនាទីនិងការចូលរួមអនុវត្តសកម្មភាពការងារកសិកម្ម របស់បុរសនិងស្ត្រី
- ដើម្បីលើកកម្ពស់ការយល់ដឹងតួនាទីយេនឌ័រ និងការខុសគ្នារបស់បុរស និងស្ត្រីពីចូលរួមសកម្មភាពនានា និងសម្រាប់ធ្វើផែនការសកម្មភាពតាមតម្រូវការរបស់បុរស និងស្ត្រី។

**វិធីសាស្ត្រ:**

- សំនួរបំផុសគំនិត ពិភាក្សាក្រុម បង្ហាញរូប
- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់

**សម្ភារះ**

- ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត
- តារាងវិភាគតួនាទីយេនឌ័រលើកសិកម្ម
- តារាងតម្រូវការជាយុទ្ធសាស្ត្រ និងជាក់ស្តែងរបស់យេនឌ័រ

**រយះពេលះ**

- ៦០ នាទី

**ដំណើរការះ**

១. អ្នកសម្របសម្រួលបិតតារាង វិភាគតួនាទីយេឌ័រ នៅលើក្រដាសផ្ទាំងធំ
២. អ្នកសម្របសម្រួលពន្យល់ពីតារាងវិភាគតួនាទីយេនឌ័រគឺ ភ្ជាប់ទំនាក់ទំនងកត្តាសកម្មភាពនានា ស្ត្រី បុរស
៣. អ្នកសម្របសម្រួល បែងចែកក្រុមបុរស និងក្រុមស្ត្រី ឱ្យវិភាគពីតួនាទី និងចូលរួមអនុវត្ត សកម្មភាពនានារបស់ពួកគាត់
៤. អ្នកសម្របសម្រួលសួរសំណួរសកម្មភាពចូលរួមគ្រប់សកម្មភាព កសិកម្មនីមួយៗ ជីវភាពរស់នៅ និងសកម្មភាពសេដ្ឋកិច្ចរបស់ស្ត្រី ឬបុរស
៥. អ្នកសម្របសម្រួល រៀបចំគូសតារាងវិភាគ តួនាទីយេនឌ័រលើកសិកម្ម និងសួរឲ្យក្រុម បុរស និងក្រុមស្ត្រីឆ្លើយនិងកំណត់សកម្មភាពនានា និងវិភាគ ភាគរយនៃការចូលរួមការងារ របស់ស្ត្រី និង បុរស ដូចជា៖

- ផលិតកម្មស្រូវ បន្លែ
- ការរៀបចំដី
- ការគ្រប់គ្រងដំណាំ
- ការប្រមូលផល

- ការចិញ្ចឹកសត្វមាន់ទា ជ្រូក គោ។ល។
- ការស្រោចស្រពការថែទាំប្រព័ន្ធស្រោចស្រព។ល។

**ឧទាហរណ៍: តារាងវិភាគតួនាទីយេនឌ័រលើកសិកម្ម (ដំណាំស្រូវនៅតំបន់ទំនាប)**

| សកម្មភាព | ប្រុស | ស្ត្រី | តម្រូវការអន្តរាគមន៍ចាំបាច់ជាក់ស្តែង |
|---|---|---|---|
| I. **សកម្មភាពមានកម្រៃ (ជាឧទាហរណ៍)** | | | |
| **១.សកម្មភាពការងារដាំដុះ** | | | |
| -ការជ្រើសរើសពូជ | | | |
| -ការរៀបចំដី | 100% | | |
| -ការដាំដុះ | 50% | 50% | |
| -ការថែទាំ និងគ្រប់គ្រងដំណាំ | | 100% | |
| -ការប្រមូលផល | 100% | | |
| -ការសម្អាត និងសម្ងួត | 100% | | |
| -ការដឹកជញ្ជូនផលិតផល | 30% | 70% | |
| -ការទំនាក់ទំនងឈ្មួញលក់ផលិតផល | | | |
| **២. សកម្មភាព ចិញ្ចឹមសត្វ** | | | |
| ១.ចិញ្ចឹមជ្រូក | | | |
| -ការជ្រើសរើសពូជ | | | |
| -ការសាងសង់ទ្រុង | | | |
| -ការផ្តល់ចំណី | | | |
| -ការអនាម័យ និងថែទាំ | | | |
| -ការចាក់ថ្នាំការពារ | | | |
| -ការទំនាក់ទំនងឈ្មួញលក់ផលិតផល | | | |
| ២.ចិញ្ចឹមមាន់ | | | |
| -ការជ្រើសរើសពូជ | | | |
| -ការសាងសង់ទ្រុង | | | |
| -ការផ្តល់ចំណី | | | |
| -ការអនាម័យ និងថែទាំ | | | |

| | | | |
|---|---|---|---|
| -ការចាក់ថ្នាំការពារ | | | |
| -ការទំនាក់ទំនងឈ្មួញលក់ផលិតផល | | | |
| ចិញ្ចឹមគោ | 10% | 90% | |
| **៣.ការចញ្ចឹមត្រី** | | | |
| -ការជ្រើសរើសពូជត្រី | | | |
| -ការគ្រប់គ្រងទឹក | 10% | 90% | |
| -ការផ្តល់ចំណីត្រី | | | |
| -លក់ផលិតផលត្រី | | | |
| II- **ការងារមិនមានតម្លៃ** | | | |
| បោកគក់ | | | |
| ដាំស្ល | | | |
| ថែទាំ និងសំអាត់ផ្ទះសំបែង | | | |
| ថែទាំក្មេង | | | |
| ថែទាំមនុស្សចាស់ | 100% | | |

៦. អ្នកសម្របសម្រួលពន្យល់ និយមន័យ: **តម្រូវការជាយុទ្ធសាស្ត្រ និងជាក់ស្តែងរបស់យេនឌ័រ**

- **តម្រូវការជាក់ស្តែងរបស់យេនឌ័រ**: ទាក់ទងនឹងតម្រូវការចាំបាច់ និងសម្ភារជីវិតរស់នៅប្រចាំថ្ងៃ (ស្បៀងអាហារ ទឹក ប្រាក់ចំណូល)
- **តម្រូវការជាយុទ្ធសាស្ត្រយេនឌ័រ:** ជាតម្រូវការរយៈពេលវែង (ឧ. ការកសាងរចនាសម្ព័ន្ធសង្គម)។

៧. អ្នកសម្របសម្រួល សួរ ពន្យល់ លើកឧទាហរណ៍និងកត់ត្រា តម្រូវការជាយុទ្ធសាស្ត្រ និងជាក់ស្តែងរបស់យេនឌ័រ:

**ឧទាហរណ៍: តម្រូវការជាយុទ្ធសាស្ត្រ និងជាក់ស្តែងរបស់យេនឌ័រ**

| តម្រូវការចាំបាច់ជាក់ស្តែង | តម្រូវការជាយុទ្ធសាស្ត្រ |
|---|---|
| • បណ្តុះបណ្តាលលើផលិតកម្មដំណាំ<br>• បណ្តុះបណ្តាលលើផលិតកម្មសត្វ<br>• បណ្តុះបណ្តាលពីបច្ចេកទេសស្រោចស្រពថ្មី<br>• សាងសង់អាងស្តុកទឹក។ល។<br>• ម៉ាស៊ីនបូបទឹកតូចៗ<br>• ពូជដំណាំធន់ | • ការទទួលបានឥណទាន<br>• ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី<br>• បណ្តុះបបណ្តាលសហគ្រិនភាព<br>• បណ្តុះបណ្តាលជំនាញថ្មីៗដល់ស្ត្រី<br>• បង្កើតជាសហគមន៍កសិកម្ម<br>• ក្រុមផលិតពូជ។ |

| | |
|---|---|
| • ពូជសត្វ និងថ្នាំការពារ<br>• អណ្តូងទឹកស្អាត។ល។ | |

៨. អ្នកសម្របសម្រួល សួរកសិករ មានសំណួរ ឬទេ?

# យេនឌ័រ និងអំណាច

**គោលបំណង**:
- បង្ហាញអ្នកចូលរួមអំពីអំណាចសំខាន់ៗដែលស្ត្រីមាន ដើម្បីជួយដល់ស្ត្រីឲ្យបានដឹង និងហ៊ាន ចរចារជាមួយប្តី និងគ្រួសារ ឬសហគមន៍
- បង្ហាញអ្នកចូលរួមឲ្យយល់ដឹងថា សមត្ថភាព និងជំនាញសម្រាប់ប្រកបរបរចិញ្ចឹមជីវិត គឺជាអំណាចរបស់ស្ត្រី

**វិធីសាស្ត្រ**:
- សំនួរបំផុសគំនិត  សរសេរលើក្រដាសផ្ទាំងធំ  បង្ហាញរូប
- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់

**សម្ភារៈ**:  ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត រូប

**រយៈពេល**:  ៦០នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលបង្ហាញពីចំណងជើង និងគោលបំណងមេរៀន

**២. ពិភាក្សាស្វែងរកឱកាសបង្កើនសមត្ថភាពរបស់ស្ត្រី (៣០នាទី)**

- អ្នកសម្របសម្រួលបែងចែកក្រុមពិភាក្សាជា២ក្រុមដើម្បីពិភាក្សាសំនួរ

ក្រុម១៖ តើមានផលប្រយោជន៍អ្វីខ្លះ បើស្ត្រីរកប្រាក់ចំណូលបាន?
ក្រុម២៖ ផលប្រយោជន៍បើស្ត្រីក្លាយជាអ្នកដឹកនាំក្រុម ឬដឹកនាំ សហគមន៍?

- ទុកពេល១៥នាទីសម្រាប់ការពិភាក្សា ។ ចប់ម៉ោង ស្នើឲ្យតំណាងក្រុមឡើងបង្ហាញ ។
- អ្នកសម្របសម្រួលបង្ហាញចំណុចខាងក្រោម៖

**ផលប្រយោជន៍ប្រសិនបើស្ត្រីរកប្រាក់បាន**
- ធ្វើឲ្យជីវភាពគ្រួសារធូរធារជាងមុន
- គ្រួសារមានភាពថ្លៃថ្នូ និងមានសុភមង្គល
- កូនបានរៀនសូត្រខ្ពង់ខ្ពស់
- កាត់បន្ថយអំពើហឹង្សា និងភាពក្រីក្រ
- សហគមន៍មានភាពរីកចម្រើនជាលំដាប់
- មានភាពក្លាហានក្នុងការសម្រេចចិត្តចាត់ចែងប្រាក់ចំណូល
- សង្គមទទួលស្គាល់

## ផលប្រយោជន៍ប្រសិនបើស្ត្រីក្លាយជាអ្នកដឹកនាំក្រុម ឬដឹកនាំសហគមន៍

- ដឹងពីព័តមានផ្សេងៗទាក់ទងនឹងការរកចំណូល ចំណេះដឹង និងជំនាញផ្សេងៗ
- មានភាពក្លាហានក្នុងការបញ្ចេញមតិ និងហ៊ាននិយាយស្តីទាមទាផ្សេងៗ
- មានទំនាក់ទំនងល្អជាមួយប្រជាជនក្នុងសហគមន៍
- ទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មីៗ
- មានការផ្លាស់ប្តូឥរិយាបទ និងផ្នត់គំនិតក្នុងការរស់នៅ
- មានឱកាសក្លាយជាអ្នកដឹកនាំក្នុងសហគមន៍
- ក្លាយជាជនគំរូ និងគ្រួសារគំរូ
- អាចចែករំលែកបទពិសោធន៍ល្អៗជាមួយស្ត្រីផ្សេងទៀត
- លើកឡើងពីបញ្ហា ឬកង្វល់របស់ស្ត្រី និងកុមារដើម្បីស្វែងរកដំណោះស្រាយ
- ក្លាយជាអ្នករកជំនួយពីអង្គការ ឬស្ថាប័ននានាដើម្បីអភិវឌ្ឍន៍សហគមន៍

សមត្ថភាព និងជំនាញសម្រាប់ប្រកបរបរចិញ្ចឹមជីវិត និងធ្វើកិច្ចការនានាក្នុងសហគមន៍ គឺជាអំណាច ឬជាសិទ្ធរបស់ស្ត្រី មិនមានអ្នកណាម្នាក់អាចរារាំង ឬដកហូតអំណាចនោះ ពីស្ត្រីបានទេ។ ស្ត្រីត្រូវហ៊ាននិយាយជាមួយប្តី និងក្រុមគ្រួសារ ឬសហគមន៍ដើម្បីប្រើប្រាស់អំណាច ឬសិទ្ធរបស់ខ្លួន។

(លើករូបនេះបង្ហាញ)



- អ្នកសម្របសម្រួលចែកអ្នកចូលរួមជា៣ក្រុមដើម្បីធ្វើការពិភាក្សា

> - **ក្រុមទី១៖** តើស្ត្រីត្រូវចរចារជាមួយគ្រួសារយ៉ាងដូចម្តេច ដើម្បីទទួលបានឱកាសចេញរកប្រាក់ចំណូលល្អប្រសើរ និងអាចចូលរួមការងារផ្សេងៗក្នុងសហគមន៍?
> - **ក្រុមទី២៖** តើស្ត្រីត្រូវចរចារជាមួយអាជ្ញាធរយ៉ាងដូចម្តេច ដើម្បីទទួលបានឱកាសចេញរកប្រាក់ចំណូលល្អប្រសើរ និងអាចចូលរួមការងារផ្សេងៗក្នុងសហគមន៍?
> - **ក្រុមទី៣៖** តើស្ត្រីត្រូវចរចារជាមួយឈ្មួញយ៉ាងដូចម្តេច ដើម្បីអាចរកទីផ្សារល្អប្រសើរសម្រាប់លក់ផលិតផល?

- អ្នកសម្របសម្រួលទុកពេល១៥នាទីសម្រាប់ក្រុមនិមួយៗពិភាក្សា
- អស់ម៉ោង សុំឲ្យក្រុមទាំង២ឡើងបង្ហាញ និងសុំឲ្យមានការបំពេញបន្ថែមប្រសិនបើមាន

**៣. ពិភាក្សាស្វែងរកឱកាសរកប្រាក់ចំណូល និងធ្វើកិច្ចការផ្សេងៗតាមសហគមន៍របស់ស្ត្រី (៣០នាទី)**

- អ្នកសម្របសម្រួលបង្ហាញអ្នកចូលរួមថា៖ **ស្ត្រីត្រូវពិភាក្សា ឬចចារជាមួយក្រុមគ្រួសារ អាជ្ញាធរ និងឈ្មួញកណ្តាលដូចខាងក្រោម៖**

**១. ចចារជាមួយក្រុមគ្រួសារដើម្បីទទួលបានឱកាសចេញរកប្រាក់ចំណូលល្អប្រសើរ និងអាចចូលរួមការងារផ្សេងៗក្នុងសហគមន៍៖**

- កំណត់អ្វីដែលត្រូវនិយាយឲ្យបានច្បាស់លាស់
- រកពេលវេលាសមស្របដើម្បីនិយាយ
- បង្ហាញពីផលប្រយោជន៍នៃអ្វីដែលខ្លួនកំពុងធ្វើ
- អញ្ជើញក្រុមគ្រួសារចូលរួមក្នុងសកម្មភាពដែលខ្លួនកំពុងធ្វើ
- ពិភាក្សាសុំជំនួយពីអ្នកដែលមានឥទ្ធិពលក្នុងសហគមន៍ឲ្យជួយនិយាយ/ពន្យល់ក្រុមគ្រួសារបន្ថែមទៀត
- ព្យាយាមធ្វើឲ្យចេញជាលទ្ធផលដើម្បីបង្ហាញដល់ក្រុមគ្រួសារ

**២. ចចារជាមួយអាជ្ញាធរ៖**

- កំណត់អ្វីដែលត្រូវនិយាយឲ្យបានច្បាស់លាស់
- ប្រមូលព័ត៌មានជុំវិញអ្វីដែលត្រូវនិយាយ
- ធ្វើការជម្រាបដល់អាជ្ញាធរស្តីពីការសុំជួប និងគោលបំណងនៃការជួប និងរកពេលវេលាសមស្របដើម្បីជួបជាមួយអាជ្ញាធរ
- បង្ហាញពីអ្វីដែលត្រូវនិយាយឲ្យបានច្បាស់លាស់ ខ្លី ងាយយល់ និងចំចំណុច
- ស្នើរសុំការអន្តរាគមន៍ពីអាជ្ញាធរ និងកំណត់ពេលវេលាឬបុគ្គលពាក់ពន្ធ័សម្រាប់តាមដានបន្ត។

**៣.ចរចារជាមួយឈ្មួញយ៉ាងដូចម្តេច ដើម្បីអាចរកទីផ្សារល្អប្រសើរសម្រាប់លក់ផលិតផល៖**

- ដឹងថាឈ្មួញត្រូវការផលិតផលបែបណា
- ស៊ើបតម្លៃទីផ្សាឲ្យបានច្រើនប្រភពដើម្បីងាយស្រួលសម្រេចចិត្ត និងចចារជាមួយឈ្មួញ
- ស្វែងរកឈ្មួញឲ្យបានច្រើនប្រភព
- បង្ហាញឈ្មួញពីគុណភាពនៃផលិតផលរបស់ខ្លួន
- លក់ផលិតផលជាក្រុមក្នុងភូមិ ដើម្បីទទួលបានតម្លៃខ្ពស់
- ធ្វើកិច្ចសន្យាលក់ ឬទិញជាមួយឈ្មួញ។

# ការផ្តល់ភាពអង់អាចដល់ស្ត្រី

**គោលបំណង**:

- បង្ហាញអ្នកចូលរួមអំពីភាគីសំខាន់ៗដែលទាក់ទងនឹងការផ្តល់ឱកាស និងផ្តល់តម្លៃដល់ស្ត្រី

**វិធីសាស្ត្រ**:

- សំនួរបំផុសគំនិត
- សរសេរលើក្រដាសផ្ទាំងធំ
- បង្ហាញរូប និង លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់

**សម្ភារៈ**: ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត រូបភាព
**រយៈពេល**: ៦០នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលបង្ហាញពីចំណងជើង និងគោលបំណងមេរៀន

២. អ្នកសម្របសម្រួលពន្យល់ ***តើត្រូវផ្តល់ភាពអង់អាចដល់ស្ត្រីនិងកុមារីដោយរបៀបណា***?

- ***ការផ្តល់ភាពអង់អាច*** គឺជាការបណ្តុំនៃការផ្លាស់ប្តូរ នៃតម្រូវការសម្រាប់ស្ត្រី ដើម្បីទទួលបាននូវសិទ្ធិពេញលេញជាមនុស្ស។ ជាការរួមបញ្ចូលគ្នានៃការផ្លាស់ប្តូរនៃសេចក្តីប្រាថ្នា និងសមត្ថភាពរបស់ស្ត្រីជាមួយនឹងមជ្ឈដ្ឋានជុំវិញដែលមានឥទ្ធិពលលើនាង និងមនុស្សផ្សេងៗដែលនាងត្រូវទំនាក់ទំនងប្រចាំថ្ងៃ។

  **ការផ្តល់ភាពអង់អាចដល់ស្ត្រី= ការផ្លាស់ប្តូរ(ក្នុង)សង្គម**

៣. អ្នកសម្របសម្រួលពន្យល់ពី **ចំណុចសំខាន់៣ នៃការផ្តល់អំណាចដល់ស្ត្រី**




**១. បុគ្គល (ស្ត្រីខ្លួនឯង)**: មានន័យថាការផ្តល់សិទ្ធអំណាចដល់ស្ត្រីនៅកម្រិតបុគ្គល ដោយផ្តល់ឱ្យពួកគេនូវជំនាញចំណេះដឹង និងភាពជឿជាក់។ ស្ត្រីនិងកុមារីអាចបង្កើតឱ្យមានការផ្លាស់ប្តូរយូរអង្វែងប្រសិនបើពួកគេមានឱកាសទទួលបាននូវការអប់រំ ទទួលបានសេវាសុខភាពត្រឹមត្រូវ អាចរកប្រាក់ចំណូល និងដឹកនាំនៅក្នុងសហគមន៍របស់ពួកគេ។ ឆ្លងកាត់ការផ្លាស់ប្តូរក្នុងការត្រួតពិនិត្យ ធនធានក្នុងគ្រួសារ និងរវាងសមាជិកគ្រួសារ។

**២. ទំនាក់ទំនង**: ជាបុគ្គល ដែលស្ត្រី និងក្មេងស្រីមានទំនាក់ទំនងក្នុងការរស់នៅ រួមមានទាំង ប្តី កូន បង ប្អូន ឪពុកម្តាយ អ្នកជិតខាង សាសនា រដ្ឋាភិបាល និងអាជ្ញាធរគ្រប់កម្រិត។

**៣. រចនាសម្ព័ន្ធ**: ជារចនាសម្ព័ន្ធសង្គមដែលស្ត្រីរស់នៅ រួមបញ្ចូលទាំងច្បាប់វប្បធម៌ ប្រពៃណី ជំនឿ ឋានៈក្នុងសង្គម ជាតិសាសន៍ និងយេនឌ័រ បរិបទក្នុងសង្គមវប្បធម៌ និងគោលនយោបាយ ច្បាប់ថ្មី ដែលលើកកម្ពស់សមភាពយេនឌ័រ វាមានន័យថាការផ្លាស់ប្តូរលក្ខខណ្ឌសង្គមរបស់ស្ត្រីដែលមានទំនាក់ទំនងដ៏សំខាន់ចំពោះជីវិតរបស់ស្ត្រី ។

## ៤. ពិភាក្សាស្វែងរកអ្នកពាក់ពន្ធ័សំខាន់ៗជាមួយនឹងស្ត្រី (២០នាទី)

- អ្នកសម្របសម្រួលចែកអ្នកចូលរួមជា២ក្រុមដើម្បីពិភាក្សា

**ក្រុមទី១៖** តើសមាជិកគ្រួសារត្រូវផ្តល់តម្លៃ និងផ្តល់ឱកាសដល់ស្ត្រីតាមវិធីណាដើម្បីឲ្យស្ត្រីមានឱកាសរកប្រាក់ចំណូល និងមានមុខមាត់ មានតួនាទីក្នុងសហគមន៍?

**ក្រុមទី២៖** តើសហគមន៍ត្រូវផ្តល់តម្លៃ និងផ្តល់ឱកាសដល់ស្ត្រីតាមវិធីណាដើម្បីឲ្យស្ត្រីមានឱកាសរកប្រាក់ចំណូល និងមានមុខមាត់ មានតួនាទីក្នុងសហគមន៍?

- អ្នកសម្របសម្រួលទុកពេល៣០នាទីសម្រាប់ក្រុមនីមួយៗពិភាក្សា
- អស់ម៉ោង សុំឲ្យក្រុមទាំង២ឡើងបង្ហាញ និងសុំឲ្យមានការបំពេញបន្ថែមប្រសិនបើមាន
- អ្នកសម្របសម្រួលធ្វើការសំយោគ៖

ដើម្បីឲ្យស្ត្រីមានឱកាសរកប្រាក់ចំណូល និងមានមុខមាត់ មានតួនាទីក្នុងសហគមន៍ស្ត្រីត្រូវការ២ចំណុចៈ

១.ចំណេះដឹង ជំនាញ សមត្ថភាពផ្ទាល់ខ្លួន បូកផ្សំនឹងភាពជឿជាក់ និងការតស៊ូអត់ធ្មត់

២. ការផ្តល់ឱកាស និងផ្តល់តម្លៃពីក្រុមគ្រួសារ និងសហគមន៍

(លើករូបនេះបង្ហាញ)




សមាជិកគ្រួសារ និងសហគមន៍ត្រូវផ្តល់តម្លៃ និងផ្តល់ឱកាសដល់ស្ត្រី ដើម្បីឲ្យស្ត្រីមានពេលវេលាគ្រប់គ្រាន់រកប្រាក់ចំណូល និងបំពេញកិច្ចការផ្សេងៗក្នុងសហគមន៍បានល្អ។

(លើករូបនេះបង្ហាញ)




- អ្នកសម្របសម្រួលសួរអ្នកចូលរួម នូវគំនិតមួយចំនួនៈ

> - ការរួមចំណែករបស់បុរស ដែលជាប្តី ជាឪពុក ជាពូ ក្នុងការជួយរំលែក ការងារ ផ្ទះសំបែង
> - ការផ្តល់ឱកាស និងលទ្ធភាពឲ្យស្ត្រីបានចូលរួម វគ្គបណ្តុះបណ្តាល ការសិក្សា អប់រំផ្សេងៗ
> - ការផ្តល់ឱកាស និងលទ្ធភាពឲ្យស្ត្រីបានចូលរួមការងារដឹកនាំសហគមន៍: ដឹកនាំការប្រជុំក្រុម ការចែករំលែកចំណេះដឹង ការផ្សព្វផ្សាយផ្សេងៗ ការចូលរួមក្នុងវេទិការផ្សេងៗ
> - **ការផ្តល់ឱកាស និងលទ្ធភាព ឲ្យស្ត្រីបានចូលរួមដឹកនាំក្នុងសកម្មភាពសេដ្ឋកិច្ចៈ**
>   - ដឹកនាំធ្វើផែនការ និងសម្រេចចិត្តក្នុងការងារអាជីវកម្ម-មុខរបរទទួលទាន
>   - ទំនាក់ទំនងទីផ្សារ ទំនាក់ទំនងចរចារជាមួយឈ្មួញ ផ្នែកឯកជន និងដៃគូរកស៊ីផ្សេងៗ រួម និងការធ្វើដំណើរចេញឆ្ងាយពីភូមិ ក្នុងគោលបំណងភ្ជាប់បណ្តាញ អាជីវកម្ម និងទំនាក់ទំនង ការប្រកបរបរចិញ្ចឹមជីវិតឲ្យកាន់តែប្រសើរជាងមុន
> - **ការរួមចំណែករបស់អាជ្ញាធរ មន្ទីរពាក់ព័ន្ធ (បង្កើតបរិយាកាសគាំពារឲ្យស្ត្រីអាចចូលរួមដឹកនាំការងារសង្គម និងដឹកនាំការងារប្រកបរបរចិញ្ចឹមជីវិត)**
>   - ជំរុញនិងគាំពារការចងក្រងក្រុមស្ត្រីតាមភូមិ
>   - សម្រួលបែបបទ-ការចាប់ផ្តើមរបរអាជីវកម្ម និងការគាំពារការចាប់ផ្តើមអាជីវកម្ម: កម្ចីការប្រាក់ទាប.......
>   - ភ្ជាប់បណ្តាញទីផ្សារ និងការជួយរកឈ្មួញឲ្យបានច្រើន.......
>   - ការគៀងគរគារគាំពារ និងជួយដោះស្រាយបញ្ហាប្រឈម ពីបណ្តាអង្គការស្ថាប័ន មន្ទីរ ផ្នែកឯកជន និងវិស័យពាក់ព័ន្ធផ្សេងៗ

៥. អ្នកសម្របសម្រួលនិយាយបន្ត៖

ដូច្នេះមេរៀនថ្ងៃនេះបានចប់ហើយ។ លោកពូ អ្នកមីងបានដឹងពីផលប្រយោជន៍ដែលស្ត្រីចូលរួមរកប្រាក់ចំណូល និងធ្វើជាអ្នកដឹកនាំក្នុងសហគមន៍រួចហើយ និងដឹងពីរបៀបដែលអាចជួយឲ្យស្ត្រី មានឱកាសចូលរួមរកប្រាក់ចំណូល និងធ្វើជាអ្នកដឹកនាំក្នុងសហគមន៍ផងដែរ។ ដូច្នេះ យើងខ្ញុំសង្ឃឹមថាស្ត្រីដែលរស់នៅក្នុងសហគមន៍របស់លោកពូ អ្នកមីងនិងទទួលបានឱកាសចូលរួមរកប្រាក់ចំណូល និងធ្វើជាអ្នកដឹកនាំក្នុងសហគមន៍ល្អប្រសើរ ព្រោះបើស្ត្រីនៅទន់ខ្សោយ នោះបន្ទុកជាច្រើននឹងធ្លាក់ទៅលើបុរស និងសហគមន៍ជាអ្នកទទួលខុសត្រូវ។

៦.អ្នកសម្របសម្រួលសួរសិក្ខាកាមតើមានសំណួរ នូវអ្វីដែលគេមិនទាន់យល់ច្បាស់ដែរឬទេ ?

# សំណួរសាកល្បងក្រោយវគ្គបណ្តុះបណ្តាល

**គោលបំណង**: ដើម្បីវាស់ស្ទង់ចំណេះដឹងរបស់កសិករក្រោយពេលទទួលវគ្គបណ្តុះបណ្តាល

**វិធីសាស្ត្រ**: អ្នកសម្របសម្រួលសួរសំណួរដែលបានសរសេររួចដោយឲ្យសិក្ខាកាមលើកដៃឆ្លើយ និងសំណួរ និងកត់ចំនួនអ្នកឆ្លើយក្នុងក្រដាស

**សម្ភារៈ**: ក្រដាសសំណួរសាកល្បង ប៊ិច ឬ ខ្មៅដៃ

**រយៈពេល**: ១០នាទី

**ដំណើរការ**:

១.អ្នកសម្របសម្រួលប្រាប់សិស្សថាអ្នកទាំងអស់គ្នាបានសិក្សាពេញមួយថ្ងៃទាក់ទង និងចំណុចសំខាន់ក្នុងការផ្តល់ឱកាសដល់ស្ត្រីចូលរួមក្នុងតួនាទីដឹកនាំសេដ្ឋកិច្ចក្នុងគ្រួសារ សូមអ្នកទាំងអស់គ្នាឆ្លើយដោយផ្ទាល់មាត់ ដើម្បីវាស់វែងចំណេះដឹងអ្នកទាំងអស់គ្នាថាតើអ្នកបានយល់ច្បាស់ពិតប្រាកដដែរឬទេ?

២.អ្នកសម្របសម្រួលសួរសំណួរ៣សំណួរបានបានរៀបចំស្រេចហើយទាក់ទង និងមេរៀនទាំងអស់ឲ្យអ្នកចូលរួមឆ្លើយ

៣. អ្នកសម្របសម្រួលកត់ត្រាក្នុងក្រដាសអ្នកចំនួនអ្នកដែលឆ្លើយត្រូវ និងចំនួនអ្នកឆ្លើយខុស និងសរុបដាក់ពិន្ទុនៅពេលក្រោយ

៤.អ្នកសម្របសម្រួលបញ្ជាក់ពីចំលើយខុស ឬ ត្រូវឲ្យសិក្ខាកាមយល់ច្បាស់លាស់។

# ការវាយតម្លៃដោយកសិករ

**គោលបំណង**: ដើម្បីឲ្យកសិករចូលរួមវាយតម្លៃសកម្មភាព និងគុណភាពនៃការបណ្តុះបណ្តាលប្រចាំថ្ងៃ និងចូលរួមធ្វើការកែលំអរចំណុចខ្វះខាត ក្នុងគោលបំណងធ្វើយ៉ាងណាឲ្យវគ្គបណ្តុះបណ្តាលកាន់តែទទួលបានជោគជ័យប្រកបដោយប្រសិទ្ធិភាព។

**រយៈពេល** : ៥ នាទី

**វិធីសាស្រ្ត** : បិទក្រដាសផ្ទាំងធំ និងឲ្យកសិករឡើងគូស

**សម្ភារៈ** : ក្រដាសផ្ទាំងលំហាត់

**ទីកន្លែង** : កន្លែងបណ្តុះបណ្តាលដែលស្ងាត់មិនមានភាពអ៊ូអរ

**ដំណើរការ** :

១. អ្នកសម្របសម្រួល ចែក លើកទឹកចិត្តឲ្យកសិករចូលរួមក្នុងការវាយតម្លៃវគ្គទាំងអស់

២. ការវាយតម្លៃធ្វើឡើងដោយឡើងគូសលើក្រដាសផ្ទាំងធំ។

# សំណួរសាកល្បង មុន និងក្រោយវគ្គបណ្តុះបណ្តាល

ឈ្មោះ............................ភេទ ប្រុស □ ស្រី□ មុនវគ្គ □ ក្រោយវគ្គ □
ភូមិ...............ឃុំ..................ស្រុក

**សូមអ្នកឆ្លើយថា ចម្លើយមួយណា ត្រឹមត្រូវ ឬ ខុស**

១. ប្តី ម្តាយ ឪពុក មិនបានផ្តល់ឱកាសឲ្យស្រ្តីចូលរួមសកម្មភាពក្នុងសហគមន៍ដោយគេគិតថាមិនចាំបាច់ឬ មិនមានប្រយោជន៍ ស្តីបន្ទោស ប្រើពាក្យមិនសមរម្យ វាយដំស្រ្តីប្រសិនបើនៅតែចូលរួមអនុវត្ត។ ទាំងអស់នេះចាត់ទុកថាជាការរើសអើងដល់ស្រ្តី?

ត្រឹមត្រូវ □ ខុស □

២.ប្តី ឪពុក ពូ ជួយរំលែក ការងារផ្ទះសំបែង ផ្តល់ឱកាសឲ្យស្រ្តីបានចូលរួម វគ្គបណ្តុះបណ្តាល ការងារ ដឹកនាំក្រុម ចែករំលែកចំណេះដឹង វេទិកាផ្សេងៗ ជួយធ្វើផែនការ និងសម្រេចចិត្តក្នុងការងារអាជីវកម្ម-មុខរបរទទួលទាន នេះចាត់ជាការជួយឲ្យស្រ្តីមានឱកាសរកប្រាក់ចំណូល និងមាន មុខ មាត់ មានតួនាទី ក្នុងសហគមន៍ស្រ្តី?

ត្រឹមត្រូវ □ ខុស □

៣. ដើម្បីទទួលបានឱកាសរកប្រាក់ចំណូលល្អប្រសើរ អាចធ្វើការងារផ្សេងៗតាមសហគមន៍ ស្រ្តីត្រូវតែក្លាហាន មានជំនាញ ក្នុងការពិភាក្សា និងចរចារ ជាមួយៈ

- ក្រុមគ្រួសារ
- អាជ្ញាធរ
- ឈ្មួញកណ្តាល

ត្រឹមត្រូវ □ ខុស □

៤.ផលប្រយោជន៍ចំបងប្រសិនបើស្រ្តីរកប្រាក់ចំណូលបាន និងធ្វើការសម្រេចចិត្តក្នុងការចាយវាយថវិកា ?

- ធ្វើឲ្យជីវភាពគ្រួសារធូរធារជាងមុន
- គ្រួសារមានភាពថ្លៃថ្នូ និងមានសុភមង្គល
- កូនបានរៀនសូត្រខ្ពង់ខ្ពស់
- កាត់បន្ថយអំពើហឹង្សា និងភាពក្រីក្រ
- សហគមន៍មានភាពរីកចំរើនជាលំដាប់
- មានភាពក្លាហានក្នុងការសម្រេចចិត្តចាត់ចែងប្រាក់ចំណូល
- សង្គមទទួលស្គាល់។

ត្រឹមត្រូវ □ ខុស □

# ទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល ប្រចាំថ្ងៃរបស់កសិករ

១.ភូមិ...............................ឃុំ.........................ស្រុក.............................

២.ឈ្មោះវគ្គបណ្តុះបណ្តាលៈ ..........................................................................................................

៣.កាលបរិច្ឆេទនៃវគ្គបណ្តុះបណ្តាលៈ ...................................................................................................

៤.សូមធ្វើការវាយតម្លៃវគ្គបណ្តុះបណ្តាលដោយគូស (✓) នូវក្នុងកន្លែងដែលអ្នកពេញចិត្តៈ

| លរ | ពិពណ៌នា | ១<br>☹ | ២<br>😐 | ៣<br>☺ |
|---|---|---|---|---|
| ១ | ការពន្យល់ និង ការឆ្លើយសំណួររបស់អ្នកសម្របសម្រួល | | | |

# តារាងកំណត់ត្រាសង្ខេបលទ្ធផលនៃការពិភាក្សាតាមក្រុមសម្រាប់អ្នកសម្របសម្រួល

កាលបរិច្ឆេទ៖ ..........................

ទីកន្លែង៖ ភូមិ …………………….  ឃុំ …………………………………….ស្រុក....................................ខេត្ត......................................

| ប្រធានបទ | សំណួរ | ចម្លើយ |
|---|---|---|
| **លំហាត់ចាប់ផ្តើម** | នៅក្នុងសហគមន៍របស់អ្នក តើបុរសភាគច្រើនធ្វើកិច្ចការអ្វី ? | |
| | នៅក្នុងសហគមន៍របស់អ្នក តើស្ត្រីភាគច្រើនធ្វើកិច្ចការអ្វី? | |
| **ការពិភាគយេនឌ័រ** | វាជារឿងធម្មតា ប្រសិនបើស្ត្រីមិនជួយរកប្រាក់ចំណូល និងរស់នៅពឹងលើប្តី | |
| | បុរសអាចទៅរកស៊ីនៅឆ្ងាយបាន ឯស្ត្រីវិញមិនអាចទៅបានទេ | |
| | ស្ត្រីមិនអាចចាត់ចែងការងារបានល្អដូចបុរសទេ | |
| | បុរសស័ក្តសមកាន់តួនាទីធំៗក្នុងសហគមន៍ ដូចជាមេឃុំ ឬមេភូមិជាដើមព្រោះបុរស មានសមត្ថភាព និងមានពេលវេលាគ្រប់គ្រាន់ | |
| | ទោះស្ត្រីធ្វើជាមេភូមិ មេឃុំ ឬអ្នកដឹកនាំសហគមន៍ ក៏មិនអាចធ្វើការបានល្អ ដូចបុរសដែរ | |

| | | |
|---|---|---|
| **ការរើសអើងទាក់ទង នឹង យេនឌ័រ** | តើក្រៅពីការងារផ្ទះសម្បែង និងផ្នត់គំនិតមួយចំនួនដែលរាំងស្ទះស្ត្រី តើស្ត្រីទទួលរងនូវការគៀបសង្កត់ ឬការរើសអើងអ្វីខ្លះទៀត ? | |
| **ការវិភាគតួនាទីយេនឌ័រ** | ការវិភាគតួនាទីយេនឌ័រលើកសិកម្ម | |
| | តើមានផលប្រយោជន៍អ្វីខ្លះ បើស្ត្រីរកប្រាក់ចំណូលបាន? | |
| | ផលប្រយោជន៍បើស្ត្រីក្លាយជាអ្នកដឹកនាំក្រុម ឬដឹកនាំ សហគមន៍? | |
| **យេនឌ័រ នឹងអំណាច** | **ក្រុមទី១៖** តើស្ត្រីត្រូវចរចារជាមួយគ្រួសារយ៉ាងដូចម្តេច ដើម្បីទទួលបានឱកាសចេញរកប្រាក់ចំណូលល្អប្រសើរ និងអាចចូលរួមការងារផ្សេងៗក្នុងសហគមន៍? | |
| | តើស្ត្រីត្រូវចរចារជាមួយអាជ្ញាធរយ៉ាងដូចម្តេចដើម្បីទទួលបានឱកាសចេញរកប្រាក់ចំណូលល្អប្រសើរ និងអាចចូលរួមការងារផ្សេងៗក្នុងសហគមន៍? | |
| | តើស្ត្រីត្រូវចរចារជាមួយឈ្មួញយ៉ាងដូចម្តេច ដើម្បីអាចរកទីផ្សារល្អប្រសើរសម្រាប់លក់ផលិតផល? | |
| **ការផ្តល់ភាពអង់អាច ដល់ស្ត្រី** | តើសមាជិកគ្រួសារត្រូវផ្តល់តម្លៃ និងផ្តល់ឱកាសដល់ស្ត្រីតាមវិធីណាដើម្បីឲ្យស្ត្រីមានឱកាសរក | |

| | | |
|---|---|---|
| | ប្រាក់ចំណូល និងមានមុខមាត់ មានតួនាទីក្នុងសហគមន៍? | |
| | តើសហគមន៍ត្រូវផ្តល់តម្លៃ និងផ្តល់ឱកាសដល់ស្ត្រីតាមវិធីណាដើម្បីឲ្យស្ត្រីមានឱកាសរកប្រាក់ចំណូល និងមានមុខមាត់ មានតួនាទីក្នុងសហគមន៍? | |

# វគ្គបណ្តុះបណ្តាល ស្តីពីតួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម

**គោលបំណង:**

- បង្កើនការយល់ដឹងសម្រាប់អនុវត្តន៍ជាក់ស្តែងក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងយុទ្ធសាស្ត្រនានារបស់ក្រសួងកសិកម្ម
- យល់ដឹងពីតួនាទីនិងការចូលរួមអនុវត្តសកម្មភាពការងារកសិកម្ម របស់បុរសនិងស្ត្រី
- ដើម្បីលើកកម្ពស់ការយល់ដឹងតួនាទីយេនឌ័រ និងការខុសគ្នារបស់បុរស និងស្ត្រីពីចូលរួមសកម្មភាពនានា
- ធ្វើការឆ្លុះបញ្ចាំងអំពីការរស់នៅ ការប្រកបរបរចិញ្ចឹមជីវិត និងតួនាទីក្នុងសហគមន៍របស់ស្ត្រីជនបទដែលបាត់បង់ឱកាស
- ស្វែងរក និងគៀងគរការចូលរួមគាំទ្រ ការលើកកម្ពស់ ការទទួលស្គាល់ និងឲ្យតម្លៃស្ត្រីក្នុងសកម្មភាពចូលរួមរកប្រាក់ ចំណូល និងសកម្មភាពដឹកនាំក្រុម ឬសហគមន៍ ពីសំណាក់ដៃគូរបុរសសហគមន៍ មន្ទីរវិស័យ ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធមូលដ្ឋាន ។

**ការរំពឹងទុក:**

- សហគមន៍នឹងបានដឹងពីផលប្រយោជន៍នៃការចូលរួមរកប្រាក់ចំណូល និង សកម្មភាព ដឹកនាំក្រុម ឬសហគមន៍របស់ស្ត្រី
- សហគមន៍បានដឹងពីបុគ្គលសំខាន់ៗដែលចូលរួមគាំទ្រ ការលើកកម្ពស់ ការទទួលស្គាល់ និងឲ្យតម្លៃស្ត្រីក្នុងសកម្មភាពចូលរួមរកប្រាក់ ចំណូល និងសកម្មភាពដឹកនាំក្រុម ឬ សហគមន៍
- សហគមន៍បានដឹងពីរបៀបចូលរួមគាំទ្រ ការលើកកម្ពស់ ការទទួលស្គាល់ និងឲ្យតម្លៃស្ត្រី ក្នុងសកម្មភាពចូលរួមរកប្រាក់ ចំណូល និងសកម្មភាពដឹកនាំក្រុម ឬសហគមន៍។

**ខ្លឹមបណ្តុះបណ្តាល**

**ស្តីពី តួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម**

ថ្ងៃ ទី.....................ខែ...............ឆ្នាំ ២០១៧

| ពេលវេលា/ម៉ោង | ប្រធានបទ | វិធីសាស្ត្រ | សំភារះ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| **ថ្ងៃ ទី១** | | | | |
| ០៧:៣០-០៧:៤០ (១០នាទី) | **១.ការណែនាំឲ្យស្គាល់គ្នាទៅវិញទៅមក** | - ចាប់ដៃគូ<br>- និយាយរឿងប្រាប់គ្នាទៅវិញទៅមក | ក្រដាសផ្ទាំងធំ ក្រដាសពណ៌កាត់ ជារាងមូល ហ្វឺត ស្កុត | គ្រូបណ្តុះបណ្តាល |
| ០៧:៤០-០៨:០៥ (១០នាទី) | **២.សំណួរសាកល្បងមុនវគ្គបណ្តុះបណ្តាល** | - សំន្ទរបំផុសគំនិត<br>- ធ្វើបទបង្ហាញ និងអានឯកសារ | គោលបំណងនៃវគ្គ សរសេរលើក្រដាសផ្ទាំងធំ ស្កុត | គ្រូបណ្តុះបណ្តាល |
| ០៨:០៥-០៨:១៥ (១០នាទី) | **៣.គោលបំណង ការរំពឹងទុក និងរបៀបវារះ** | - សំន្ទរបំផុសគំនិត<br>- ធ្វើបទបង្ហាញ និងអានឯកសារ | គោលបំណងនៃវគ្គ សរសេរលើក្រដាសផ្ទាំងធំ ស្កុត | គ្រូបណ្តុះបណ្តាល |
| ០៨:១៥-០៨:២០ (០៥នាទី) | **៤.គោលការណ៍ក្រុម ឬវគ្គ** | - សំន្ទរបំផុសគំនិត<br>- សរសេរលើក្រដាសផ្ទាំងធំ<br>- ក្រដាសរូបអាក្បកិរិយា ដែលអ្នកចូលរួមមិនគួរធ្វើ | ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត | គ្រូបណ្តុះបណ្តាល |
| ០៨:២០-១០:៥០ (២ ម៉ោង ៣០នាទី) | **៥.គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម និងតួនាទីភារកិច្ចអ្នកពាក់ព័ន្ធ** | - បទបង្ហាញ ពន្យល់ បំផុសគំនិត និងក្រុមពិភាក្សា | ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត | គ្រូបណ្តុះបណ្តាល |

| | | | | |
|---|---|---|---|---|
| **១០:៥០-១១:០៥ (១៥នាទី)** | **សម្រាកអាហារសម្រន់** | | | |
| ១១:០៥-១១:៣៥ (៣០នាទី) | **៦.លំហាត់ចាប់ផ្តើម** | - ពិភាក្សាក្រុម<br>- ក្រុមបង្ហាញលទ្ធផលនៃការពិភាក្សា<br>- សរសេរលើក្រដាសផ្ទាំងធំ<br>- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់ | ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត ផ្ទាំងរូបភាព | គ្រូបណ្តុះបណ្តាល |
| **១១:៣៥-១៣:០០** | **សម្រាកបាយថ្ងៃត្រង់** | | | |
| ១៣:០០-១៤:០០ (៦០នាទី) | **៧.ផ្នត់គំនិតយេនឌ័រ** | - សំនួរបំផុសគំនិត<br>- លំហាត់ក្រុម<br>- ពិភាក្សាដោយប្រើរូប<br>- សរសេរលើក្រដាសផ្ទាំងធំ<br>- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់ | ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត ផ្ទាំងរូបភាព | គ្រូបណ្តុះបណ្តាល |
| ១៤:០០-១៤:១០ (១០នាទី) | បន្តមេរៀន | | | គ្រូបណ្តុះបណ្តាល |
| ១៤:១០-១៥:១០ (៦០នាទី) | **៨.ការវិភាគយេនឌ័រ** | - លំហាត់សន្ទនាស្វែងយល់ពីផ្នត់គំនិតរបស់អ្នកចូលរួម<br>- សំនួរបំផុសគំនិត<br>- សរសេរលើក្រដាសផ្ទាំងធំ<br>- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់ | ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត ផ្ទាំងរូបភាព | គ្រូបណ្តុះបណ្តាល |
| ១៥:១០-១៦:០០ (៦០នាទី) | **៨.ការរើសអើងនឹងយេនឌ័រ** | - សំនួរបំផុសគំនិត<br>- ពិភាក្សាក្រុម | ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត | គ្រូបណ្តុះបណ្តាល |

| | | | | |
|---|---|---|---|---|
| | | - បង្ហាញរូប<br>- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់ | | |
| **១៦:០០-១៦:១៥** | **សម្រាកអាហារសម្រន់** | | | |
| ១៦:១៥-១៧:០០<br>(៤៥នាទី) | **៩.ការវិភាគយេនឌ័រក្នុងរបរកសិកម្ម** | - សំនួរបំផុសគំនិត ពិភាក្សាក្រុម បង្ហាញរូប<br>- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់ | -ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត<br>-តារាងវិភាគតួនាទីយេនឌ័រលើកសិកម្ម<br>-តារាងតម្រូវការជាយុទ្ធសាស្ត្រ និងជាក់ស្តែងរបស់យេនឌ័រ | គ្រូបណ្តុះបណ្តាល |
| **ថ្ងៃទី២** | | | | |
| ០៨:០០-០៨:១៥<br>(១៥នាទី) | **បន្តមេរៀន៖ ការវិភាគយេនឌ័រក្នុងរបរកសិកម្ម** | - សំនួរបំផុសគំនិត ពិភាក្សាក្រុម បង្ហាញរូប<br>- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់ | -ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត<br>-តារាងវិភាគតួនាទីយេនឌ័រលើកសិកម្ម<br>-តារាងតម្រូវការជាយុទ្ធសាស្ត្រ និងជាក់ស្តែងរបស់យេនឌ័រ | គ្រូបណ្តុះបណ្តាល |
| ០៨:១៥-០៩:១៥<br>(៦០នាទី) | **១០.យេនឌ័រ និងអំណាច** | - សំនួរបំផុសគំនិត<br>- សរសេរលើក្រដាសផ្ទាំងធំ<br>- បង្ហាញរូប<br>- លើកទឹកចិត្តឲ្យមានការបញ្ចេញមតិយោបល់ | ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត | គ្រូបណ្តុះបណ្តាល |
| ០៩:១៥-១០:១៥<br>(៦០នាទី) | **១១.ការផ្តល់ភាពអង់អាចដល់ស្ត្រី** | - សំនួរបំផុសគំនិត<br>- សរសេរលើក្រដាសផ្ទាំងធំ<br>- បង្ហាញរូប | ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត | គ្រូបណ្តុះបណ្តាល |

| | | | | |
|---|---|---|---|---|
| | | - បង្ហាញ ៣ចំណុចនៃការផ្តល់ភាពអង់អាចដល់ស្ត្រី<br>- បែងចែកក្រុមពិភាក្សា<br>- ក្រុមបង្ហាញលទ្ធផលនៃការពិភាក្សា | | |
| **១០:១៥-១០:៣០ (១៥នាទី)** | **សម្រាកអាហារសម្រន់** | | | |
| ១០:៣០-១០:៤៥ (១០នាទី) | **១២.សំណួរសាកល្បងក្រោយវគ្គបណ្តាល** | អ្នកសម្របសម្រួលសួរសំណួរដែលបានសរសេររួចជារួម ដោយឲ្យសិក្ខាកាមលើកដៃ និងកត់ក្នុងក្រដាស | ក្រដាសសំណួរសាកល្បងក្រោយវគ្គបណ្តុះបណ្តាល | គ្រូបណ្តុះបណ្តាល |
| ១០:៤៥-១០:៥០ (៥នាទី) | **១៣.វាយតម្លៃវគ្គបណ្តុះបណ្តាល** | អ្នកសម្របសម្រួលឲ្យសិក្ខាកាមទៀងគូសក្នុងតារាងវាយតម្លៃ | ក្រដាសតារាងវាយតម្លៃវគ្គ | គ្រូបណ្តុះបណ្តាល |

# ឯកសារយោង


១. ឯកសារមេរៀនស្តីពី "ពង្រឹងសមត្ថភាព និងភាពអង់អាចដល់តំណាងក្រុមស្ត្រី"ផលិតដោយក្រុមការងារគម្រោងឱកាសអាជីវកម្មសម្រាប់ស្ត្រីវ័យក្មេង (YWIB) អង្គការឃែរកម្ពុជា ឆ្នាំ២០១៣ ។

២. ឯកសារមេរៀនស្តីពី "យេនឌ័រ" ផលិតដោយក្រុមការងារគម្រោងលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការងារសាងសង់ និងថែទាំផ្លូវជនបទ អង្គការឃែរកម្ពុជា ឆ្នាំ ២០១៤ ។

៣. ឯកសារមេរៀនស្តីពី "យេនឌ័រ" ផលិតដោយក្រុមការងារគម្រោងលើកកម្ពស់ស្ត្រីក្នុងវិស័យឧស្សាហកម្មស្រាបៀរ អង្គការឃែរកម្ពុជា ។

៤. ឯកសារការបណ្តុះបណ្តាលគ្រូបង្គោលពី ការផ្តល់ឱកាសឲ្យស្ត្រីចូលរួមក្នុងតួនាទីដឹកនាំសេដ្ឋកិច្ច អង្គការឃែរកម្ពុជា ឆ្នាំ ២០១៤។

៥. សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ក្នុងកសិកម្ម អង្គការ FAO និង DFAT Operational Guideline note ឆ្នាំ ២០១៥។

៦. គោលនយោបាយផ្សព្វផ្សាយកសិកម្មកម្ពុជា នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ឆ្នាំ ២០១៥។

៧. គោលការណ៍ណែនាំពីការវាយតម្លៃតម្រូវការកសិករ កម្មវិធី ASPIRE នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម/អគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខែ មករា ឆ្នាំ ២០១៧។

៨. គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម ២០១៦ -២០២០ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខែ តុលា ឆ្នាំ ២០១៥។

៩. នារីរតនៈទី៤: ផែនការយុទ្ធសាស្ត្រ ដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ២០១៤ -២០១៨ ក្រសួងកិច្ចការនារី។